ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍បូកសរុបលទ្ធផលការងារ
# គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
# ប្រចាំឆ្នាំ២០២៥ និងទិសដៅអនុវត្តឆ្នាំ២០២៦

ខែ មីនា ឆ្នាំ ២០២៦



# មាតិកា


ទំព័រ

១. សេចក្តីផ្តើម ........ ១

២. បេសកកម្ម និងភារកិច្ច របស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា........ ១

៣. ផែនការយុទ្ធសាស្ត្រ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងគណៈកម្មការទន្លេមេគង្គ... ២

៣.១ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ........ ២

៣.២ គណៈកម្មការទន្លេមេគង្គ ........ ៣

៤. វឌ្ឍនភាពការងារ និងសមិទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៥........ ៤

៤.១ លទ្ធផលការងារ........ ៤

៤.២ បញ្ហាប្រឈម ........ ១៩

៥. ការបូកសរុប និងសេចក្តីសន្និដ្ឋាន ........ ២០

៦. ទិសដៅការងារអនុវត្តបន្តឆ្នាំ២០២៦ ........ ២១

## ១. សេចក្តីផ្តើម

**គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា** (គ.ជ.ទ.ម.ក) ត្រូវបានបង្កើតឡើងតាមសេចក្តីសម្រេច លេខ៣១៩/៨០ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៨០ របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។ សេចក្តីសម្រេចនេះ ត្រូវបានជំនួសដោយព្រះរាជក្រឹត្យលេខ នស/រកត/០៩០៩/៩៤៣ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការកែសម្រួល និងការធ្វើនិយតភាពកាបង្កើត គ.ជ.ទ.ម.ក ដែលបានចែងថាៈ គ.ជ.ទ.ម.ក **គឺជាស្ថាប័នជាតិមួយដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់រាជរដ្ឋាភិបាលសម្រាប់សម្របសម្រួលក្នុងការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ**។ ដើម្បីចូលរួមអនុវត្តបេសកកម្មជាយុទ្ធសាស្ត្រនេះ គ.ជ.ទ.ម.ក បានរៀបចំផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ របស់ខ្លួនជាបន្តបន្ទាប់ ដែលផែនការយុទ្ធសាស្ត្របច្ចុប្បន្នគឺឆ្នាំ ២០២៤-២០២៨ ដើម្បីរួមចំណែកគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ឆ្នាំ២០២៤-២០២៨ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា និងដើម្បីបន្តចូលរួមអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេឆ្នាំ២០២១-២០៣០ របស់ MRC ឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យនៅថ្នាក់ជាតិ "**កិច្ចសហប្រតិបត្តិការកាន់តែរឹងមាំក្នុងក្របខណ្ឌ "ទន្លេមេគង្គតែមួយ ស្មារតីតែមួយ" ឆ្ពោះទៅសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្នុងអាងទន្លេមេគង្គ**" និងនៅថ្នាក់តំបន់ "**អាងទន្លេមេគង្គ មានវិបុលភាពផ្នែកសេដ្ឋកិច្ច យុត្តិធម៌សង្គម បរិស្ថានល្អ និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ**។

## ២. បេសកកម្ម និងភារកិច្ច របស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

គ.ជ.ទ.ម.ក ជាសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានបេសកកម្ម សម្របសម្រួលក្នុងការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ ប្រកបដោយនិរន្តរភាព។ **គ.ជ.ទ.ម.ក** មានមុខងារ និងភារកិច្ច ដូចខាងក្រោមៈ

- ជាសេនាធិការ ជំនួយការឱ្យរាជរដ្ឋាភិបាលលើរាល់ការគ្រប់គ្រង ការពិនិត្យពិចារណា ការសិក្សា និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ដើម្បីបុព្វហេតុសេដ្ឋកិច្ចជាតិ និងផលប្រយោជន៍របស់ប្រជាជន និងបុព្វហេតុសន្តិភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- ធ្វើការសិក្សា ពិនិត្យពិចារណា ហើយលើកសំណើជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យសម្រេចលើរាល់បញ្ហាទាំងឡាយណាដែលទាក់ទងនឹងការធ្វើផែនការ ការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រង ការថែរក្សា ការពារ និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ ប្រកបដោយនិរន្តរភាព
- សម្របសម្រួល និងសហការអនុវត្តជាមួយក្រសួង-ស្ថាប័នជាតិ ក្នុងការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ ប្រកបដោយនិរន្តរភាព
- រួមសហការជាមួយក្រសួង-ស្ថាប័ន រាជធានី-ខេត្តក្រុងពាក់ព័ន្ធ ដើម្បីអនុវត្តសេចក្តីសម្រេចទាំងឡាយរបស់រាជរដ្ឋាភិបាល ស្តីពីអាងទន្លេមេគង្គ
- ពង្រឹងកិច្ចសហប្រតិបត្តិការ ជាមួយនឹងគណៈកម្មាធិការជាតិទន្លេមេគង្គ នៃបណ្តាប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ ជាមួយបណ្តាដៃគូអភិវឌ្ឍន៍ និងអង្គការតំបន់និងអន្តរជាតិផ្សេងៗ ក្នុងការពិនិត្យពិចារណា ការសិក្សា ការអភិវឌ្ឍ ការគ្រប់គ្រង និងការថែរក្សាធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ ឱ្យបានសមស្របទៅនឹងផលប្រយោជន៍ដ៏សមរម្យរបស់បណ្តាប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ និងដោយត្រឹមត្រូវតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីអាងទន្លេមេគង្គ
- ធ្វើទំនាក់ទំនង សម្របសម្រួលជាមួយគណៈកម្មការទន្លេមេគង្គ និងដៃគូអភិវឌ្ឍន៍ដើម្បីស្វែងរកថវិកាជំរុញការសិក្សា និងការអភិវឌ្ឍគម្រោងឱ្យបានឆាប់រហ័សទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់

- កៀរគររកមធ្យោបាយ និងធនធានដើម្បីរួមចំណែកក្នុងការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងវិស័យធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ
- អប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងដល់អ្នកពាក់ព័ន្ធ និង
- បំពេញភារកិច្ចផ្សេងទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

## ៣- ផែនការយុទ្ធសាស្ត្រគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និង គណៈកម្មការទន្លេមេគង្គ

### ៣.១ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

ដោយរាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ឆ្នាំ ២០២៤-២០២៨ និងដើម្បីចូលរួមចំណែកគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ លើអាទិភាពការងារដែលពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានទឹក និងអាងទន្លេឱ្យមានប្រសិទ្ធភាព និងដើម្បីគាំទ្រ និងពង្រឹងការចូលរួមរបស់កម្ពុជាសម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍប្រកបដោយចីរភាពក្នុងអាងទន្លេមេគង្គ ទាំងនៅជាតិ និងថ្នាក់តំបន់, គ.ជ.ទ.ម.ក បានធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្ររបស់ខ្លួន សម្រាប់ឆ្នាំ២០២៤-២០២៨ ដោយក្នុងនោះ បានកំណត់នូវទិសដៅនិងកិច្ចការជាអាទិភាពចំនួន ៥ រួមមាន៖ ទី១) ពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារឱ្យកាន់តែប្រសើរ ទី២) គាំទ្រ និងពង្រឹងកិច្ចប្រតិបត្តិការការងារ និងការគ្រប់គ្រងធនធានទឹក និងអាងទន្លេប្រកបដោយប្រសិទ្ធភាពដោយមានការចូលរួម និងកិច្ចសហការ, ទី៣) ពង្រឹង លើកកម្ពស់កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ ដើម្បីជានាបាននូវការអភិវឌ្ឍ និងការគ្រប់គ្រងអាងទន្លេ ប្រកបដោយចីរភាព ទី៤) លើកកម្ពស់ការយល់ដឹងសាធារណៈ និងការផ្សព្វផ្សាយដើម្បីពង្រឹងការចូលរួម និងប្រើប្រាស់ផលិតផល MRC សម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍន៍តាមវិស័យ ដោយកិច្ចសហប្រតិបត្តិការ និងមានការចូលរួម និងទី៥) ពង្រឹងប្រសិទ្ធភាព នៃការពិនិត្យតាមដាន និងធ្វើឱ្យប្រសើរកិច្ចដំណើរការជាប្រចាំ។ ផែនការយុទ្ធសាស្ត្រ ត្រូវបានអនុវត្តតាមរយៈផែនការការងារប្រចាំឆ្នាំរបស់ គ.ជ.ទ.ម.ក ដែលសម្របសម្រួលអនុវត្តដោយអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក និងដោយមានការចូលរួម កិច្ចសហការ និងការគាំទ្រពីក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធផ្សេងទៀត។



ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ, គ.ជ.ទ.ម.ក ធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នជាសមាជិក លេខាធិការដ្ឋាន MRC និងជាមួយបណ្តាគណៈកម្មាធិការជាតិទន្លេមេគង្គនៃប្រទេសជាសមាជិកផ្សេងទៀត រួមមានឡាវ ថៃ និងវៀតណាម ក្នុងការអនុវត្តឱ្យមានប្រសិទ្ធភាព និងប្រកបដោយជោគជ័យនូវកិច្ចព្រមព្រៀងមេគង្គឆ្នាំ ១៩៩៥ និងបណ្តានីតិវិធី ស្តីពីគ្រប់គ្រងការប្រើប្រាស់ទឹករបស់ MRC និងក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ យុទ្ធសាស្ត្រអភិវឌ្ឍន៍អាង ដោយផ្អែកលើគោលការណ៍នៃការគ្រប់គ្រងធនធានទឹកចម្រុះ ការងារវិមជ្ឈការមុខងារស្នូលនៃការគ្រប់គ្រងអាងទន្លេ និងបណ្តាគម្រោង និងកម្មវិធីកិច្ចសហប្រតិបត្តិការតំបន់ ឆ្លងដែន សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពក្នុងអាងទន្លេមេគង្គ។

## ៣.២ គណៈកម្មការទន្លេមេគង្គ (Mekong River Commission-MRC)

MRC គឺជាស្ថាប័នអន្តររដ្ឋាភិបាល ត្រូវបានបង្កើតឡើងតាមរយៈកិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការ ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពនៃអាងទន្លេមេគង្គ ដែលបានចុះហត្ថលេខានាថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៩៥ ដោយប្រទេសជាសមាជិក រួមមានៈ កម្ពុជា ឡាវ ថៃ និងវៀតណាម។

MRC មានបេសកកម្ម ក្នុងការសម្របសម្រួល និងលើកកម្ពស់កិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ នៃការអភិវឌ្ឍ ការប្រើប្រាស់ ការគ្រប់គ្រង និងការអភិរក្សប្រកបដោយចីរភាពនៃធនធានទឹកនិងធនធានពាក់ព័ន្ធក្នុងអាងទន្លេមេគង្គ រួមមានការស្រោចស្រព វារីអគ្គិសនី នាវាចរណ៍ ការត្រួតពិនិត្យទឹកជំនន់ ជលផលជាដើម ក្នុងលក្ខណៈមួយដើម្បីធ្វើឱ្យការប្រើប្រាស់ពហុបំណង បានកាន់តែប្រសើរឡើង និងផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមកក្នុងចំណោមបណ្តាប្រទេសតាមដងទន្លេមេគង្គ និងដើម្បីកាត់បន្ថយផលប៉ះពាល់អាក្រក់ដែលអាចកើតឡើងពីបាតុភូតធម្មជាតិ និងពីសកម្មភាពរបស់មនុស្ស។ ដើម្បីអនុវត្តបេសកកម្មរបស់ខ្លួន MRC បានរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេ និងផែនការយុទ្ធសាស្ត្រ និងបានធ្វើបច្ចុប្បន្នភាពតាមដំណាក់កាលជាបន្តបន្ទាប់ ដោយបច្ចុប្បន្ន MRC បាននិងកំពុងអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេឆ្នាំ២០២១-២០៣០ និងផែនការយុទ្ធសាស្ត្រឆ្នាំ២០២១-២០២៥។ ផែនការយុទ្ធសាស្ត្រឆ្នាំ២០២១-២០២៥ បានកំណត់នូវកម្មវិធីការងារជាអាទិភាព ដែល MRC ត្រូវអនុវត្តដើម្បីជំរុញកិច្ចសហប្រតិបត្តិការតំបន់ក្នុងចំណោមប្រទេសជាសមាជិក ជាមួយប្រទេសដៃគូសន្ទនា (ចិន និងមីយ៉ាន់ម៉ា) ដៃគូអភិវឌ្ឍន៍ អង្គការតំបន់និងអន្តរជាតិ និងដៃគូសហការពាក់ព័ន្ធផ្សេងទៀត សំដៅសម្រេចឱ្យបាននូវការអភិវឌ្ឍ ការប្រើប្រាស់ ការគ្រប់គ្រង និងការអភិរក្សធនធានទឹកនិងធនធានពាក់ព័ន្ធក្នុងអាងទន្លេមេគង្គប្រកបដោយចីរភាពស្របតាមគោលបំណងដែលមានចែងក្នុងកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥។ យុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេ និងផែនការយុទ្ធសាស្ត្ររបស់ MRC ខាងលើ បានកំណត់នូវអាទិភាពជាយុទ្ធសាស្ត្រចំនួន ៥ ផ្តោតលើផ្នែកៈ ទី១) **ផ្នែកបរិស្ថានៈ** ថែរក្សាមុខងារអេកូឡូស៊ីនៃអាងទន្លេមេគង្គ ទី២) **ផ្នែកសង្គមៈ** ផ្តល់លទ្ធភាពដែលអាចប្រើប្រាស់ទឹក និងធនធានពាក់ព័ន្ធនៃអាងទន្លេមេគង្គប្រកប ដោយបរិយាបន្ន ទី៣) **ផ្នែកសេដ្ឋកិច្ចៈ** លើកកម្ពស់ការអភិវឌ្ឍវិស័យធនធានទឹក និងវិស័យពាក់ព័ន្ធឱ្យមានលក្ខណៈប្រសើរបំផុត និងប្រកបដោយចីរភាព ទី៤) **ផ្នែកការប្រែប្រួលអាកាសធាតុៈ** ពង្រឹងភាពធន់ទប់ទល់នឹងហានិភ័យនៃអាកាសធាតុ,



គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតធ្ងន់ធ្ងរ និងទី៥) **ផ្នែកកិច្ចសហប្រតិបត្តិការ:** ពង្រឹងកិច្ចសហប្រតិបត្តការក្នុងចំណោមប្រទេសក្នុងអាងទន្លេមេគង្គទាំងអស់ និងអ្នកពាក់ព័ន្ធនានា។

នៅក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការMRC ប្រទេសជាសមាជិកនីមួយៗ មានគណៈកម្មាធិការជាតិទន្លេមេគង្គ (National Mekong Committee-NMC) របស់ខ្លួន ដែលនៅកម្ពុជា គឺ**គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា** (Cambodia National Mekong Committee-CNMC) ដែលមានតួនាទី ក្នុងការសម្របសម្រួលនៅថ្នាក់ជាតិ និងក្របខ័ណ្ឌតំបន់ លើការរៀបចំ ការអនុវត្ត ការពិនិត្យតាមដាន ការវាយតម្លៃលើផែនការ យុទ្ធសាស្រ្ត គម្រោង កម្មវិធី និងសកម្មភាពការងារនានារបស់ MRC។

**រចនាសម្ព័ន្ធ និងយន្តការសម្របសម្រួលការងារ**







## ៤. វឌ្ឍនភាពការងារ និងសមិទ្ធផលសម្រេចបានក្នុងឆ្នាំ ២០២៥

ក្នុងនាមជាស្ថាប័នថ្នាក់ជាតិ មានបេសកកម្មសម្របសម្រួលក្នុងការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ និងធ្វើកិច្ចសហប្រតិបត្តិការដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពក្នុងអាងទន្លេមេគង្គ, គ.ជ.ទ.ម.ក បានបំពេញការងារដោយផ្អែកលើផែនការងារឆ្នាំ២០២៥ ដោយបានអនុវត្ត និងសម្រេចបានលទ្ធផលដែលមានខ្លឹមសារសង្ខេប ដូចខាងក្រោម៖

### ៤.១ លទ្ធផលការងារ

### ក/. ការលើកកម្ពស់ប្រសិទ្ធភាពកិច្ចដំណើរការការងារស្ថាប័ន

- បានយកចិត្តទុកដាក់លើការពង្រឹង និងលើកកម្ពស់សមត្ថភាពស្ថាប័ន និងធនធានមនុស្ស ដោយបានចាត់ទុកការងារនេះ ជាតម្រូវការជាអាទិភាពសំខាន់ក្នុងការអនុវត្ត បេសកកម្ម និងការបំពេញការងារប្រចាំថ្ងៃ
- បានរៀបចំបញ្ចប់សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃ គ.ជ.ទ.ម.ក ដែលជាផ្នែកមួយនៃកំណែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ ដោយក្នុងនោះដែរ ក៏បាន

ធ្វើការកំណត់មុខតំណែងវិជ្ជាជីវៈ និងរចនាសម្ព័ន្ធរបស់ គ.ជ.ទ.ម.ក ដែលជំហានបន្តនឹងត្រូវធ្វើជូនទៅក្រសួងមុខងារសាធារណៈ ដើម្បីបន្តនីតិវិធីបន្ទាប់

- បានយកចិត្តទុកដាក់ពិនិត្យ និងតាមដានវត្តមាន ប្រចាំថ្ងៃ ខែ និងប្រចាំឆ្នាំ តាមរយៈការស្កេន QR Code និងចុះហត្ថលេខាផ្ទាល់ដៃ របស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា និងបំពេញតារាងព័ត៌មាន របស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក







- បានផ្តល់ធាតុចូល សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ដែលនៅក្នុងឯកសារផ្លូវការនេះ គ.ជ.ទ.ម.ក មានកម្មវិធីគោលនយោបាយនិងការងារជាអាទិភាព ចំនួន ៣ ដែលរួមមាន៖ ១) គាំទ្រ និងពង្រឹងកិច្ចប្រតិបត្តិការការងារនិងការគ្រប់គ្រងធនធានទឹកនិងអាងទន្លេប្រកបដោយប្រសិទ្ធភាព ២) លើកកម្ពស់កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ ដើម្បីធានាបានការអភិវឌ្ឍ និងការគ្រប់គ្រងអាងទន្លេប្រកបដោយចីរភាព និង៣) លើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការផ្សព្វផ្សាយ ដើម្បីពង្រឹងការចូលរួម និងការប្រើប្រាស់ផលិតផល MRC សម្រាប់គ្រប់គ្រង និងអភិវឌ្ឍតាមវិស័យ។ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ២០២៥ របស់គ.ជ.ទ.ម.ក ស្តីពីការចូលរួមចំណែកក្នុងការអនុវត្ត ផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក៏បានរៀបចំ និងផ្ញើជូនទៅក្រសួងផែនការ តាមសំណើផងដែរ





- បានរៀបចំកិច្ចប្រជុំសមាសភាព គ.ជ.ទ.ម.ក ប្រចាំឆ្នាំ២០២៤ និងឆ្នាំ២០២៥ ដើម្បីផ្សព្វផ្សាយ និងជម្រាបអំពីបច្ចុប្បន្នភាពនៃកិច្ចសហប្រតិបត្តិការ និងសមិទ្ធផលការងារក្នុងក្របខណ្ឌ MRC លើការគ្រប់គ្រង ការប្រើប្រាស់ ការអភិវឌ្ឍនិងការអភិរក្សធនធានទឹកនិងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ។ ក្នុងនោះដែរ ក៏បានរៀបចំទស្សនកិច្ចសិក្សាស្វែងយល់ជាក់ស្តែងស្ថានភាពទន្លេមេគង្គ បណ្តាញស្ទួលតាមដានទន្លេ និងទំនប់វារីអគ្គិសនីសេសានក្រោម២ ក្នុងភូមិសាស្ត្រខេត្តស្ទឹងត្រែង



- បានផ្តល់កិច្ចសហការ ក្នុងការរៀបចំប្រកបដោយជោគជ័យសន្និបាតបូកសរុបលទ្ធផលការងារ ក្រសួងធនធានទឹក និងឧតុនិយម គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងអាជ្ញាធរទន្លេសាប ឆ្នាំ២០២៤ និងទិសដៅអនុវត្តឆ្នាំ ២០២៥ ដែលនៅក្នុងពិធីបិទបានប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី និងជាអនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** ក្នុងនាមជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**
- បានពង្រឹងប្រសិទ្ធភាពនៃកិច្ចដំណើរការការងារ និងការគ្រប់គ្រងអង្គភាព តាមរយៈកិច្ចប្រជុំផ្ទៃក្នុងអង្គភាព និងស្ថាប័ន និងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៦-២០២៨ និងគម្រោងថវិកាឆ្នាំ២០២៦



សកម្មភាពទាំងនេះ ជាផ្នែកមួយក្នុងការងាររបស់ គ.ជ.ទ.ម.ក ដើម្បីរួមចំណែកចូលរួមគាំទ្រការអនុវត្ត យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា លើផ្នែកកំណែទម្រង់ និងការពង្រឹងអភិបាលកិច្ចស្ថាប័ន និងធនធានមនុស្ស និងការលើកកម្ពស់ប្រសិទ្ធភាពការងារ។

### ខ/. ការពង្រឹងកិច្ចដំណើរការការងារនិងកិច្ចសហប្រតិបត្តិការតំបន់ និងភាពជាដៃគូ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹក និងធនធានពាក់ព័ន្ធក្នុងអាងទន្លេមេគង្គ




- បានបន្តចូលរួមជំរុញ និងលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងឆ្នាំ២០២១-២០៣០ និងផែនការយុទ្ធសាស្ត្រឆ្នាំ២០២១-២០២៥ ក៏ដូចជាយុទ្ធសាស្ត្រ និងផែនការមេ តាមវិស័យ (ជលផល បរិស្ថាន នាវាចរណ៍ វារីអគ្គិសនី ការប្រែប្រួលអាកាសធាតុ ទឹកជំនន់ និងភាពរាំងស្ងួត ជាដើម) រួមទាំងនីតិវិធីស្តីពីការគ្រប់គ្រងការប្រើប្រាស់ទឹករបស់ MRC ។ ទន្ទឹមនឹងនោះដែរ បានសម្របសម្រួលលើការរៀបចំផែនការបុរេសកម្មតំបន់ និងការធ្វើឱ្យប្រសើរឡើងនូវក្របខ័ណ្ឌគាំទ្រការធ្វើ សេចក្តីសម្រេចចិត្ត សម្រាប់រៀបចំផែនការរួមទាំងការគ្រប់គ្រង។ ការណ៍នេះ ធ្វើឡើងដោយមានកិច្ចសហការ ការចូលរួម និងការគាំទ្រពីថ្នាក់ជាតិ និងថ្នាក់តំបន់ ដែលជាការរួមចំណែកដ៏សំខាន់ដើម្បីធានានូវការអភិវឌ្ឍការគ្រប់គ្រងនិងការអភិរក្សធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតប្រកបដោយចីរភាពក្នុងអាងទន្លេមេគង្គ




- បានសម្របសម្រួលនិងផ្តល់កិច្ចសហប្រតិបត្តិការក្នុងចំណោមប្រទេសជាសមាជិក MRC ក្នុងការចែករំលែកទិន្នន័យជលសាស្ត្រ-ឧតុនិយម ប្រតិបត្តិការទំនប់សម្រាប់គាំទ្រដល់ការគ្រប់គ្រងទឹកជំនន់ និងភាពរាំងស្ងួត ក្នុងអាងទន្លេមេគង្គមានលក្ខណៈកាន់តែប្រសើរ និងការពិនិត្យតាមដាន ការព្យាករ និងការជូនដំណឹងជាមុន មានលក្ខណៈកាន់តែសុក្រឹត្យ និងទាន់ពេលវេលា

| បណ្តាញស្ទួលតាមដានស្ថានភាពទន្លេ | ចំនួនស្ថានីយសរុបក្នុងអាងទន្លេមេគង្គក្រោម | កម្ពុជា | ឡាវ | ថៃ | វៀតណាម |
|---|---|---|---|---|---|
| ជលសាស្ត្រ | 61 | 17 | 21 | 12 | 11 |
| កករដី | 25 | 8 | 6 | 9 | 2 |
| គុណភាពទឹក | | | | | |
| ស្វ័យប្រវត្ត (Automatic) | 10 | 3 | 3 | 1 | 3 |
| ដោយដៃ (Manual) | 43 | 11 | 15 | 8 | 9 |
| សុខភាពអេកូឡូស៊ី | 36 | 10 | 12 | 8 | 6 |
| ជលផល | | | | | |
| តាមដានផលចាប់ | 37 | 11 | 12 | 6 | 8 |
| តាមដានកូនត្រីម្សៅ | 8 | 2 | 2 | 2 | 2 |
| តាមដានដាយត្រី | 1 | 1 | - | - | - |

- បានបន្តសហការ និងចូលរួមពិនិត្យតាមដានស្ថានភាពទន្លេ និងធនធានក្នុងអាង និងការធ្វើឱ្យប្រសើរបណ្តាញស្ទួលពិនិត្យតាមដានទន្លេ លើផ្នែកជលសាស្ត្រ កករដី គុណភាពទឹក សុខភាពអេកូឡូស៊ី ជលផលជាដើម ដែលផ្តល់ជាមូលដ្ឋានចំណេះដឹងបែបវិទ្យាសាស្ត្រអំពីស្ថានភាព និងនិន្នាការ បន្តជួយគាំទ្រដល់ការរៀបចំ ផែនការគ្រប់គ្រង និងការអភិវឌ្ឍអាងទន្លេ និងធនធានរួមក្នុងអាងប្រកបដោយប្រសិទ្ធភាព និងការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងមេគង្គ ឆ្នាំ១៩៩៥ នីតិវិធីគ្រប់គ្រងការប្រើប្រាស់ទឹក ផែនការ និងសកម្មភាព



ជាអាទិភាពរបស់ MRC ដើម្បីឆ្ពោះទៅសម្រេចឱ្យបាននូវការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធប្រកបដោយចីរភាព និងនិរន្តរភាពបរិស្ថាន រួមទាំងភាពធន់ការប្រែប្រួលអាកាសធាតុក្នុងអាងទន្លេមេគង្គ។ ក្នុងនោះដែរ សម្រាប់គាំទ្រដល់ការងារផ្នែកជលសាស្ត្រ-ឧតុនិយមនៅកម្ពុជា ព្រមទាំងថ្នាក់តំបន់ ក្រុមការងារកម្ពុជាដែលមានមន្ត្រីជំនាញ នៃក្រសួងធនធានទឹកនិងឧតុនិយម និងដោយមានការចូលរួមពីក្រុមមន្ត្រីជំនាញនៃលេខាធិការដ្ឋាន MRC បានចុះពិនិត្យស្ថានភាព និងជួសជុលសម្រាប់ដំណើរការប្រក្រតីនៃស្ថានីយជលសាស្ត្រ-ឧតុនិយម និងស្ថានីយតាមដានភាពរាំងស្ងួតនៅតាមបណ្តារាជធានី-ខេត្តពាក់ព័ន្ធមួយចំនួន ក្នុងអាងទន្លេមេគង្គកម្ពុជា

- បានសម្របសម្រួល និងចូលរួមពង្រឹងកិច្ចសហការក្នុងការរៀបចំនិងអនុវត្តផែនការ សកម្មភាពការងារ និងគម្រោងនៅថ្នាក់ជាតិ មានលក្ខណៈឆ្លងដែន និងក្នុងក្របខ័ណ្ឌអាង ដើម្បីរួមគ្នាដោះស្រាយបញ្ហាប្រឈមនានាដូចជាទឹកជំនន់ ភាពរាំងស្ងួត ការប្រែប្រួលរបបជលសាស្ត្រ និងគុណភាពទឹកជាដើម








- បានគាំទ្រ និងពង្រឹងកិច្ចសហការការងារ និងការគ្រប់គ្រងធនធានទឹក និងអាងទន្លេ ដោយបានរួមសហការពង្រឹង និងលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ បានកាន់តែប្រសើរថែមទៀតទាំងនៅថ្នាក់ជាតិជាមួយក្រសួង-ស្ថាប័ននិងភាគីពាក់ព័ន្ធនានា និងនៅថ្នាក់តំបន់ជាមួយលេខាធិការដ្ឋានMRC ប្រទេសជាសមាជិកផ្សេងទៀត( ឡាវ ថៃ និងវៀតណាម) ប្រទេសដៃគូសន្ទនា (ចិន និងមីយ៉ាន់ម៉ា) ដៃគូអភិវឌ្ឍន៍ និងដៃគូសហការផ្សេងទៀត
- បានយកចិត្តទុកដាក់ និងសហការជំរុញអនុវត្តលើការបញ្ជ្រាបយេនឌ័រ ក្នុងការគ្រប់គ្រងអាងទន្លេ និងធនធានទឹកចម្រុះ តាមរយៈការផ្សព្វផ្សាយ និងបង្កើនការចូលរួមរបស់ស្ត្រីក្នុងព្រឹត្តិការណ៍ពាក់ព័ន្ធនានា នៅថ្នាក់ជាតិនិងថ្នាក់តំបន់ដោយក្នុងនោះ ក៏បានចូលរួមសហការរៀបចំសៀវភៅមគ្គុទេសក៍ ស្តីពីការបញ្ជ្រាបយេនឌ័រ នៅក្នុងសកម្មភាព និងមុខងារស្នូលរបស់ MRC និងបានធ្វើការផ្សព្វផ្សាយនៅថ្នាក់ជាតិ
- ក្រុមការងារអន្តរស្ថាប័ន បានចូលរួមសហការអនុវត្តការសិក្សារួមគ្នារវាងលេខាធិការដ្ឋាន MRC និងភាគីចិន ស្តីពីបម្រែបម្រួលជលសាស្ត្រក្នុងអាងទន្លេមេគង្គ-ឡានចាង និងយុទ្ធសាស្ត្របន្ស៊ាំ ដែលការសិក្សារួមនេះ គឺក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងរួមអំពីបញ្ហាប្រឈមដែលកើតមានក្នុងអាង និងដើម្បីរួមគ្នាឆ្លើយតបបានកាន់តែប្រសើរចំពោះហានិភ័យទឹកជំនន់ និងភាពរាំងស្ងួតក្នុងអាង តាមរយៈកិច្ចខិតខំប្រឹងប្រែង និងសកម្មភាពរួមគ្នា






- ក្រុមការងារអន្តរស្ថាប័ន បានសហការអនុវត្តគម្រោងសិក្សាសាកល្បង ស្តីពីការធ្វើឱ្យប្រសើរលទ្ធភាពទទួលបានទឹកស្អាត និងបង្កើនសន្តិសុខស្បៀង នៅឃុំស្តៅ ស្រុកសេសាន ខេត្តស្ទឹងត្រែង ដោយបានតម្លើងប្រព័ន្ធឧបករណ៍ផ្គត់ផ្គង់ទឹក ក្នុងនោះសម្រាប់ទឹកស្អាតក្នុងបរិមាណ ២០០ម៣ ក្នុងមួយថ្ងៃ និងទឹកសម្រាប់កសិកម្មក្នុងបរិមាណ ១០០០ម៣ ក្នុងមួយថ្ងៃ
- រួមជាមួយប្រទេសជាសមាជិកផ្សេងទៀត (ឡាវ ថៃ និងវៀតណាម) កម្ពុជាបានបំពេញកាតព្វកិច្ចរបស់ខ្លួន អនុលោមតាមលិខិតលេខ ១៣០៧ សជណ.កស ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការបង់វិភាគទានប្រចាំឆ្នាំសម្រាប់ឆ្នាំ២០២៥ ជូនMRC សម្រាប់កិច្ចដំណើរការនៃលេខាធិការដ្ឋាន MRC និងគាំទ្រដល់កិច្ចសហប្រតិបត្តិការតំបន់ ដើម្បីការអភិវឌ្ឍ និងការគ្រប់គ្រងប្រកបដោយចីរភាពក្នុងអាងទន្លេមេគង្គ
- មន្ត្រីកម្ពុជា ១រូប ត្រូវបានចាត់បញ្ជូនទៅបម្រើការងារជាប្រធានអង្គភាពផ្នែកគាំទ្របច្ចេកទេសនៅលេខាធិការដ្ឋាន MRC សម្រាប់អាណត្តិការងាររយៈពេល ៣ឆ្នាំ (២០២៥-២០២៨) និងមានមន្ត្រីកម្ពុជា ២រូប ផ្សេងទៀត ត្រូវបានជ្រើសរើសឱ្យបម្រើការងារនៅលេខាធិការដ្ឋាន MRC ដោយក្នុងនោះ ១រូប ជាមន្ត្រីជំនាញផ្នែកលទ្ធកម្ម និង១រូបទៀត ជាមន្ត្រីជំនាញផ្នែកមូលដ្ឋានទិន្នន័យនិងប្រព័ន្ធព័ត៌មាន
- ក្រុមការងារគណៈកម្មាធិការរួមរបស់កម្ពុជា បានចូលរួមជាមួយក្រុមការងារគណៈកម្មាធិការរួមនៃប្រទេសជាសមាជិកផ្សេងទៀត(ឡាវ ថៃ និងវៀតណាម) ក្នុងកិច្ចប្រជុំក្រុមការងារគណៈកម្មាធិការរួម MRC ដើម្បីពិនិត្យវាយតម្លៃការបំពេញការងារសម្រាប់ឆ្នាំទី១ ចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២៥ របស់លោកស្រី Bousadee Santipitaks នាយិកាប្រតិបត្តិនៃលេខាធិការដ្ឋាន MRC ដោយក្នុងនោះជាលទ្ធផល គណៈកម្មាធិការរួម បានវាយតម្លៃការបំពេញការងាររបស់លោកស្រីនាយិកាប្រតិបត្តិ ក្នុងកម្រិតនិទ្ទេស "ល្អ" និងបានផ្តល់អនុសាសន៍ណែនាំលើកិច្ចការសំខាន់មួយចំនួន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចដំណើរការ និងការគ្រប់គ្រងលេខាធិការដ្ឋាន MRC និងការពង្រឹងកិច្ចសហប្រតិបត្តិការតំបន់សម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍអាងទន្លេមេគង្គប្រកបដោយប្រសិទ្ធភាព និងដោយចីរភាពបន្ថែមទៀត
- មន្ត្រីជំនាញការជាតិចំនួន ១០រូប ត្រូវបានជ្រើសរើសដើម្បីជួយគាំទ្រដល់ការងារថ្នាក់តំបន់ និងថ្នាក់ជាតិលើសកម្មភាពជាអាទិភាពមួយចំនួនរួមមាន ផែនការគ្រប់គ្រងទីជម្រាលនិងបរិស្ថាន ការគ្រប់គ្រងទឹកជំនន់និងភាពរាំងស្ងួត ការគ្រប់គ្រងនិងការប្រើប្រាស់ទឹកក្រោមដីសម្រាប់វិស័យកសិកម្ម ការតាមដានផលប៉ះពាល់សង្គមនិងវាយតម្លៃភាពងាយរងគ្រោះ ការតាមដានផ្លូវត្រី/ជណ្តើរត្រី ជាដើម
- កម្ពុជាបានផ្តល់លិខិតគាំទ្រMRC ដើម្បីក្លាយជាស្ថាប័នទទួលស្គាល់ជាផ្លូវការពីមូលនិធិបរិស្ថានសកល (Global Environment Facility -GEF) សម្រាប់ដាក់សំណើសុំការគាំទ្រពី GEF។ ការគាំទ្ររបស់កម្ពុជា បានរួមចំណែកធ្វើឱ្យ MRC ទទួលបានមូលនិធិចំនួន ១២លានដុល្លារ សម្រាប់អនុវត្តគម្រោងលើកកម្ពស់ការគ្រប់គ្រងជលផលក្នុងអាងទន្លេមេគង្គក្រោម តាមរយៈ អង្គការ IUCN ដែលបានអនុម័តពីក្រុមប្រឹក្សាមូលនិធិបរិស្ថានសកល






- ដោយមានការសម្រេចអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីរាជរដ្ឋាភិបាល និងក្នុងនាម **ឯកឧត្តម ថោ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងជាសមាជិកក្រុមប្រឹក្សា MRC តំណាងកម្ពុជា ឯកឧត្តម សូ សុភ័ទ្ទ អគ្គលេខាធិការ គ.ជ.ទ.ម.ក បានដឹកនាំគណៈប្រតិភូកម្ពុជាអន្តរក្រសួង-ស្ថាប័ន ចូលរួមប្រជុំតាមអនឡាញ ពីខេត្តសៀមរាប សម្រាប់កិច្ចប្រជុំក្រុមប្រឹក្សា MRC លើកទី៣២ និងកិច្ចប្រជុំជាមួយដៃគូអភិវឌ្ឍន៍លើកទី៣០ នៅប្រទេសថៃ ដែលជាប្រទេសម្ចាស់ផ្ទះ ក្នុងនាមជាប្រធានក្រុមប្រឹក្សា MRC សម្រាប់ឆ្នាំ២០២៥។ ក្រៅពីនេះ ក្រុមប្រតិភូកម្ពុជាអន្តរក្រសួង-ស្ថាប័ន ក៏បានចូលរួមកិច្ចប្រជុំប្រចាំឆ្នាំរបស់គណៈកម្មាធិការរួមលើកទី៥៩ និងលើកទី៦០ កិច្ចប្រជុំក្រៅផ្លូវការជាមួយដៃគូអភិវឌ្ឍន៍លើកទី១៣ និងកិច្ចប្រជុំដៃគូសន្ទនា ( ចិន និងមីយ៉ាន់ម៉ា ) លើកទី២៩។ កិច្ចប្រជុំទាំងនេះ គឺជាវេទិកាដ៏សំខាន់ដើម្បីរួមគ្នាពិនិត្យវឌ្ឍនភាពការងារដែលបានអនុវត្តនិងសម្រេចបាន ពិភាក្សាអំពីបញ្ហាប្រឈមនិងរួមគ្នាគិតគូរដោះស្រាយ និងដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការនិងភាពជាដៃគូឱ្យបានកាន់តែរឹងមាំ និងប្រសើរថែមទៀតឆ្ពោះទៅសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព ដោយធ្វើឱ្យប្រសើរផ្នែកសេដ្ឋកិច្ច សង្គម និងនិរន្តរភាពបរិស្ថានក្នុងអាងទន្លេមេគង្គ







- ក្រុមការងារអន្តរក្រសួង ស្ថាប័នកម្ពុជា បានចូលរួមវេទិការួម MRC លើកទី១៤ ដែលជាឱកាសសំខាន់សម្រាប់ប្រទេសជាសមាជិក រួមនឹងលេខាធិការដ្ឋាន MRC ពិនិត្យ និងពិភាក្សាលើវឌ្ឍនភាព និងបញ្ហាប្រឈមក៏ដូចជាមេរៀនបទពិសោធន៍ និងផែនការបន្តដើម្បីពង្រឹងនិងលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តនីតិវិធី ទាំង៥ របស់ MRC រួមមាន៖ ១. ការដោះដូរ និងចែករំលែកទិន្នន័យនិងព័ត៌មាន ២. ការពិនិត្យតាមដានការប្រើប្រាស់ទឹក ៣. ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការ



ព្រមព្រៀង ៤. ការថែរក្សាជារទឹកនៅលើទន្លេមេ និង ៥. គុណភាពទឹក ដែលនីតិវិធីប្រតិបត្តិទាំងនេះ គឺជាក្របខ័ណ្ឌអនុវត្តសំខាន់សម្រាប់គាំទ្រការគ្រប់គ្រង ការប្រើប្រាស់ ការអភិវឌ្ឍ និងការអភិរក្សប្រកបដោយចីរភាពនៃធនធានទឹក និងធនធានពាក់ព័ន្ធក្នុងអាងទន្លេមេគង្គ ក្រុមការងារអន្តរក្រសួង-ស្ថាប័ន កម្ពុជា រួមជាមួយក្រុមការងារអន្តរក្រសួងស្ថាប័ននៃប្រទេសជាសមាជិកផ្សេងទៀត( ឡាវ ថៃ និងវៀតណាម) បានរួមគ្នាពិភាក្សា និងរៀបចំឯកសារបច្ចេកទេស តាមវិស័យ/ផ្នែក មួយចំនួន រួមមាន៖




- ✓ ផែនការបុរេសកម្មតំបន់រួមបញ្ចូលទាំងការធ្វើបច្ចុប្បន្នភាពក្របខ័ណ្ឌគាំទ្រការធ្វើសេចក្តីសម្រេចចិត្ត របស់ MRC ( Proactive Regional Planning including upgrading MRC Decision Support Framework )
- ✓ ក្របខ័ណ្ឌផែនការ និងការគ្រប់គ្រងទីជម្រាលប្រកបដោយចីរភាព ក្នុងអាងទន្លេមេគង្គក្រោម និងផែនការសកម្មភាពគម្រោង (Framework for Basin-wide Planning and Management of Sustainable Watersheds of the Lower Mekong Basin and its Project Based Action Plan )
- ✓ ផែនការអនុវត្តគម្រោងពង្រឹងការគ្រប់គ្រងហានិភ័យទឹកជំនន់ និងភាពរាំងស្ងួត ក្នុងអាងទន្លេមេគង្គក្រោម ឆ្នាំ ២០២៦-២០២៩ ( Project Implementation Plan for Strengthening Flood and Drought Risk Management in the Lower Mekong Basin, 2026-2029 )




- ✓ ផែនការមេ/ផែនការសកម្មភាពរួម ផ្នែកទឹកជនន់ និងភាពរាំងស្ងួត សម្រាប់អនុអាងទន្លេសេកុង សេសាន និងស្រែពក( Flood and Drought Master Plan / Joint Action Plan for the Sekong, Sesan and Srepok Basins )
- ✓ សេចក្តីព្រាងនៃអនុស្សារណៈស្តីពីការយោគយល់គ្នាសម្រាប់កិច្ចសហប្រតិបត្តិការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹកឆ្លងដែនប្រកបដោយចីរភាព នៅតំបន់អនុអាង 9C-9T នៃអាងទន្លេមេគង្គ (Memorandum of Understanding on Cooperation for sustainable transboundary water resources management and development of the 9C-9T sub-basin of the Mekong River Basin )




- ✓ សេចក្តីព្រាងចុងក្រោយនៃគោលការណ៍ណែនាំបច្ចេកទេស សម្រាប់ការអនុវត្តនីតិវិធីស្តីពីការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (Final Draft of Technical Guidelines for the implementation of the Procedures for Notification, Prior Consultation, and Agreement - PNPCA )

- ✓ គោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រងសារពើភ័ណ្ឌប្រព័ន្ធធារាសាស្ត្រ (Guidance on Irrigation Asset Management)
- ✓ គោលការណ៍ណែនាំ ស្តីពីការស្រោចស្រពជាដំណាក់កាល/សន្សំសំចៃទឹក (Guidance on Intermittent Irrigation)







- ✓ សេចក្តីព្រាងចុងក្រោយនៃគោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រង និងប្រើប្រាស់ទឹកក្រោមដីប្រកបដោយចីរភាពសម្រាប់វិស័យកសិកម្មក្នុងអាងទន្លេមេគង្គក្រោម (Final Draft of Technical Guidance on Sustainable Groundwater Use and Management for Agriculture in the Lower Mekong River Basin)
- ✓ សៀវភៅណែនាំសុវត្ថិភាពសម្រាប់បុគ្គលិកកំពង់ផែ ស្តីពីការលើកដាក់ និងការផ្ទុកទំនិញគ្រោះថ្នាក់នៅក្នុងអាងទន្លេមេគង្គក្រោម (Safety Booklet for Port Staff on the handling and storage of dangerous goods in the Lower Mekong Basin)




- ✓ ឯកសារទស្សនទាននៃមូលនិធិអាកាសធាតុបៃតង សម្រាប់ការគ្រប់គ្រងទឹកជំនន់ និងភាពរាំងស្ងួតដែលបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងអាងទន្លេមេគង្គក្រោម (Green Climate Fund Concept Note for Climate Change Adaptation Flood and Drought Management in the Lower Mekong Basin)
- ✓ សេចក្តីព្រាងក្របខណ្ឌលំហូរទន្លេមេគង្គលើគេហទំព័រព័ត៌មាន (Mekong Flow Framework on the information web-based)




- ✓ វិធីសាស្ត្រវាយតម្លៃតម្រូវការសម្រាប់ការវិភាគចំណុចខ្វះខាត នៃផែនការគ្រប់គ្រងនៃធនធានបរិស្ថានដែលមានសារៈសំខាន់ថ្នាក់តំបន់ នៃយុទ្ធសាស្ត្រគ្រប់គ្រងបរិស្ថានក្នុងបរិបទនៃការគ្រប់គ្រងធនធានទឹកចម្រុះ ការគ្រប់គ្រងទីជម្រាល និងតម្រូវការថ្នាក់តំបន់ (Needs assessment methodology for the review and gap analysis of existing management plans for Regional Environmental Assets-REAs of the Strategy for Basin-wide Environmental Management-SBEM in the context of IWRM, watershed management and regional needs)

- ក្នុងក្របខ័ណ្ឌនៃយន្តការកិច្ចសហប្រតិបត្តិការតំបន់ផ្សេងទៀត និងជាលក្ខណៈទ្វេភាគី, គ.ជ.ទ.ម.ក បានចូលរួម និងអនុវត្តការងារដោយសម្រេចបានលទ្ធផល ដូចតទៅ៖

✓ **ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង/ជាមួយចិន៖** បានទទួលអនុវត្ត និងលើកសំណើគម្រោង រួមមាន៖

**គម្រោង បាននិងកំពុងអនុវត្តមានចំនួន ៣ ៖**

- គម្រោង "ការគ្រប់គ្រងធនធានទឹក និងធនធានពាក់ព័ន្ធឆ្លងដែនដោយមានការចូលរួមពីសហគមន៍នៅតំបន់ព្រំដែនដីសណ្ដទន្លេមេគង្គ កម្ពុជា វៀតណាម និងផ្សព្វផ្សាយបទពិសោធន៍ទទួលបានទៅតំបន់ព្រំដែនកម្ពុជា ឡាវ" (Community-based transboundary water resources and flood risks management in the Border Areas of Cambodia and Vietnam and outreach experience to the Border Areas of Cambodia and Lao PDR)
- គម្រោង "ការគ្រប់គ្រងហានិភ័យទឹកជំនន់សម្រាប់ការអភិវឌ្ឍកសិកម្ម ផ្អែកលើផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុនៅស្ទឹងសែន នៃដៃបឹងទន្លេសាប ប្រទេសកម្ពុជា" (Flood Risk Management for Agricultural Development based on Climate Change Impact Sen River, Tributary of the Tonle Sap Lake, Cambodiaនិង
- គម្រោងផ្គត់ផ្គង់ទឹកស្អាតជនបទ នៅភូមិព្រះនង្គ័ល ឃុំចំណាក្រោម ស្រុកស្ទោង ខេត្តកំពង់ធំ គឺជាគម្រោងអភិវឌ្ឍន៍មួយ ដែលត្រូវបានអនុវត្តក្នុងក្របខ័ណ្ឌ កិច្ចសហប្រតិបត្តិការ កម្ពុជា–ចិន និង Lancang–Mekong Cooperation។

**គម្រោងបានលើកសំណើមានចំនួន ៤ ៖**

- គម្រោង "ការគ្រប់គ្រងទំនាបលិចទឹកនៃបឹងទន្លេសាប ដោយផ្អែកលើម៉ូដែលជលសាស្ត្រ និងការវិភាគរបស់អ្នកពាក់ព័ន្ធក្នុងសហគមន៍ដែលបានជ្រើសរើសក្នុងខេត្តកំពង់ធំ" (Floodplain Management of the Tonle Sap Lake, based on Hydrological Model and Stakeholder Analyses in the Selected Communities in Kampong Thom Province)
- គម្រោង "ការកែលម្អអភិបាលកិច្ចទឹក ដើម្បីកាត់បន្ថយបញ្ហាប្រឈមដែលកើតឡើងដោយសារការកើនឡើងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ភាពងាយរងគ្រោះ និងហានិភ័យគ្រោះមហន្តរាយលើទឹក ប្រព័ន្ធអេកូឡូស៊ី និងសន្តិសុខស្បៀងជនបទក្នុងខេត្តកំពង់ធំ" (Improving Water Governance to mitigate emerging challenges caused by increased climate change impacts, vulnerabilities and disaster risks on water, ecosystem system and rural food security in Kampong Thom province)
- គម្រោង "ការព្យាករទឹកជំនន់ផ្អែកលើស្ថានីយត្រួតពិនិត្យទឹក ដោយប្រើបច្ចេកវិទ្យា AI សម្រាប់អាងស្ទឹងព្រែកត្នោត" (Flood Forecasting based on AI Monitoring Stations for the Prek Thnot River Basin) និង

- គម្រោង "ការលើកកម្ពស់សមត្ថភាពទិន្នន័យទឹក និងកិច្ចសន្ទនាថ្នាក់តំបន់ក្រោមក្របខណ្ឌកិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គ" (Advance Water Data Capacity and Regional Dialogue under the Lancang-Mekong Cooperation Framework)

✓ **ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ-កូរ៉េ/ជាមួយកូរ៉េ៖** បានសម្របសម្រួលនិងសហការអនុវត្តគម្រោងលើកកម្ពស់លទ្ធភាពទទួលបានទឹកស្អាត និងការបង្កើនសន្តិសុខស្បៀង នៅឃុំស្ដៅ ស្រុកសេសាន ខេត្តស្ទឹងត្រែង និងបានលើកសំណើ ១គម្រោង ស្តីពីការគ្រប់គ្រងហានិភ័យទឹកជំនន់ នៅតំបន់ទន្លេសេកុង សេសាន និងស្រែពក (3S)

✓ **ក្នុងក្របខ័ណ្ឌបណ្តាញ និងមជ្ឈមណ្ឌលបច្ចេកវិទ្យាអាកាសធាតុនៃកម្មវិធីបរិស្ថានសហប្រជាជាតិ (Climate Technology Centre and Network-CTCN of UNEP៖** បានលើកសំណើតាមរយៈក្រសួងបរិស្ថានដោយទទួលបានការគាំទ្រសម្រាប់គម្រោង "ពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុសម្រាប់ការគ្រប់គ្រងប្រព័ន្ធទឹក–ថាមពល–ស្បៀង" តាមរយៈការកែលម្អប្រព័ន្ធគាំទ្រការសម្រេចចិត្ត របស់ គ.ជ.ទ.ម.ក (Strengthening Climate Resilience of Water–Energy–Food Nexus Management through CNMC Decision Support System Upgrade)





✓ **ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-វៀតណាម៖** បានសម្របសម្រួល និងចូលរួមកិច្ចប្រជុំក្រុមការងារទ្វេភាគីរវាងកម្ពុជា និងវៀតណាម លើការអនុវត្តកិច្ចព្រមព្រៀងរវាងកម្ពុជា និងវៀតណាម ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក ដោយក្នុងនោះភាគីទាំងពីរបានពិនិត្យអំពីវឌ្ឍនភាព និងពិភាក្សារួមគ្នាដោះស្រាយបញ្ហាប្រឈមដែលបានកើតមាន និងការកំណត់នូវសកម្មភាពថ្មីៗបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្ត និងក៏បានស្នើ MRCS ឱ្យបន្តតួនាទីសម្របសម្រួល និងគាំទ្រការអនុវត្តកិច្ចព្រមព្រៀងខាងលើ។ ក្រៅពីនេះ មន្ត្រីអគ្គលេខាធិការដ្ឋាន ក៏បានចូលរួមកិច្ចប្រជុំគណៈកម្មការចម្រុះ (JC) កម្ពុជា-វៀតណាម លើកទី២១ ដើម្បីពិនិត្យវឌ្ឍនភាព និងផែនការអនុវត្តបន្តសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដោយបានពិនិត្យ និងផ្តល់ជាតុចូលសម្រាប់ការងារពាក់ព័ន្ធនឹងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា លើកិច្ចសហប្រតិបត្តិការផ្នែកបរិស្ថាន ធនធានទឹក និង ជលសាស្ត្រ-ឧតុនិយម។



✓ **ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ឡាវ៖** មន្ត្រីអគ្គលេខាធិការដ្ឋាន បានចូលរួមកិច្ចប្រជុំគណៈកម្មការចម្រុះ (JC) កម្ពុជា-ឡាវ លើកទី១៥ ដើម្បីពិនិត្យវឌ្ឍនភាព និងផែនការអនុវត្តបន្តសម្រាប់កិច្ចសហប្រតិបត្តិការ សេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដោយភាគីទាំពីរបានគូសបញ្ជាក់នូវ

ការប្តេជ្ញាចិត្តរួម ក្នុងការបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការភាពជាដៃគូដ៏សំខាន់ដើម្បីផលប្រយោជន៍រួមប្រទេសទាំងពីរ។

✓ **ក្នុងក្របខ័ណ្ឌកិច្ចសហការជាមួយដៃគូពាក់ព័ន្ធផ្សេងទៀត៖** បន្ថែមពីលើនោះ ក្រុមមន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក ក៏បានទទួលជួបពិភាក្សាការងារជាមួយភាគីពាក់ព័ន្ធមួយចំនួន មានជាអាទិ៍ក្រុមការងារធនាគារពិភពលោក ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង អង្គការ JICA ក្រុមការងារចិន និងតំណាងបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជាជាដើម ដើម្បីកសាងនិងពង្រឹងទំនាក់ទំនងនិងកិច្ចសហការការងារ ក៏ដូចជាស្វែងរកលទ្ធភាពនៃការគាំទ្រដើម្បីអនុវត្តការងារជាតម្រូវការនៅថ្នាក់ជាតិ និងថ្នាក់តំបន់ផងដែរ។



កិច្ចសហការក្នុងការរៀបចំផែនការរួម និងការធ្វើការរួមគ្នាអនុវត្តប្រកបដោយប្រសិទ្ធភាព គឺជាអាទិភាពនិងស្នូលសំខាន់សម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍន៍អាងទន្លេ និងធនធានក្នុងអាង។ ក្នុងនាមជាស្ថាប័នជាតិសម្របសម្រួលក្នុងកិច្ចសហប្រតិបត្តិការតំបន់, គ.ជ.ទ.ម.ក បានផ្តល់អាទិភាព និងយកចិត្តទុកដាក់ខ្ពស់ក្នុងការជំរុញលើកកម្ពស់កិច្ចសហការ ការចូលរួមតាមរយៈកិច្ចពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធនៅថ្នាក់ជាតិ និងក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការតំបន់ និងភាពជាដៃគូ សំដៅចូលរួមអនុវត្តផែនការ និងសកម្មភាពរួម ឱ្យបានកាន់ប្រសើរនិងប្រកបដោយប្រសិទ្ធភាពក្នុងកិច្ចខិតខំប្រឹងប្រែង និងបេសកកម្មឆ្ពោះទៅសម្រេចបាននូវគោលបំណងរួមដើម្បីការអភិវឌ្ឍដោយចីរភាពក្នុងអាងទន្លេមេគង្គសម្រាប់ប្រទេសតាមដងទន្លេ រួមទាំងកម្ពុជាផងដែរ។ ជាការកត់សម្គាល់ គឺគ្រប់ភាគីនិងដៃគូសហការ ជាពិសេសដៃគូអភិវឌ្ឍន៍ និងប្រទេសដៃគូសន្ទនា តែងបានអះអាងនូវការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការបន្តជួយគាំទ្រ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយ MRC និងប្រទេសជាសមាជិក ដើម្បីរួមគ្នាដោះស្រាយបញ្ហាប្រឈមក្នុងអាង និងឆ្ពោះទៅសម្រេចឱ្យបាននូវគោលដៅនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងតំបន់មេគង្គ។

## គ/. ការលើកកម្ពស់ការយល់ដឹងសាធារណៈ និងការផ្សព្វផ្សាយ











- បានលើកកម្ពស់ការយល់ដឹង និងផ្សព្វផ្សាយដល់ក្រសួង-ស្ថាប័ន និងអ្នកពាក់ព័ន្ធ ក៏ដូចជាសាធារណជនទូទៅ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អំពីសកម្មភាពការងារបានអនុវត្ត ឯកសារគតិយុត្ត យុទ្ធសាស្ត្រ គោលនយោបាយ ផែនការនិងសមិទ្ធផលសម្រេចបានតាមវិស័យ និងអំពីសារៈសំខាន់ ស្ថានភាព និងនិន្នាការនៃទន្លេមេគង្គ និងធនធានធម្មជាតិ សម្រាប់ជាការរួមចំណែក និងគាំទ្រដល់ការគ្រប់គ្រង ការអភិវឌ្ឍ ការប្រើប្រាស់ និងការអភិរក្សធនធានទឹក និងធនធានពាក់ព័ន្ធ ក្នុងអាងឱ្យកាន់តែប្រសើរ មានប្រសិទ្ធភាព និងប្រកបដោយចីរភាព ទាំងនៅថ្នាក់ជាតិ និងថ្នាក់តំបន់
- បានផ្សព្វផ្សាយតាមបណ្តាញទំនាក់ទំនងសង្គម និងជម្រាបជូនសមាសភាព គ.ជ.ទ.ម.ក តំណាងក្រសួង-ស្ថាប័នជាសមាជិក នូវព័ត៌មានសង្ខេបស្តីពីស្ថានភាពជលសាស្ត្រក្នុងអាងទន្លេមេគង្គ ជារៀងរាល់ថ្ងៃនៅរដូវវស្សា និងប្រចាំសប្តាហ៍នៅរដូវប្រាំង។ បន្ថែមពីលើនេះ ក៏បានជូនដំណឹងជាប្រចាំរៀងរាល់កន្លះខែម្តង នូវសេចក្តីជូនដំណឹងរបស់ក្រុមហ៊ុនវារីអគ្គិសនីវៀតណាម ស្តីពីការបញ្ចេញធារទឹកពីអាងស្តុកទឹកសេសាន៤ សេសាន៤អេ និងស្រែពក៤ ជូនដល់ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងរ៉ែនិងថាមពល អាជ្ញាធរខេត្ត និងមន្ទីរធនធានទឹកនិងឧតុនិយម និងមន្ទីររ៉ែ និងថាមពលនៃខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី
- បានរៀបចំ និងផ្សព្វផ្សាយឃ្លីបវីដេអូ ស្តីពី៖ ទន្លេមេគង្គដើម្បីការអភិវឌ្ឍដោយចីរភាពដោយក្នុងឃ្លីបវីដេអូនេះ ក្នុងនោះក៏មានការផ្សព្វផ្សាយក្នុងហ្វេសបុកផ្លូវការរបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ផងដែរ ដែលអាចចូលមើល តាមរយៈ៖ https://www.facebook.com/share/v/1AccbfYurp/?mibextid=wwXIfr



- **ឯកឧត្តម តែ ណាវុធ អនុប្រធានអចិន្ត្រៃយ៍** នៃគ.ជ.ទ.ម.ក បានផ្តល់កិច្ចសំភាសន៍ជាមួយទីភ្នាក់ងារទូរទស្សន៍ជាតិកម្ពុជា ដើម្បីផ្សព្វផ្សាយបន្តអំពីសមិទ្ធផលការងារក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ
- បានសម្របសម្រួល និងពង្រឹងបន្ថែមការចែករំលែកទិន្នន័យប្រតិបត្តិការទំនប់ក្នុងអាងទន្លេមេគង្គក្នុងចំណោមប្រទេសជាសមាជិក ដោយក្នុងនោះសម្រាប់កម្ពុជា គឺការចែករំលែកទិន្នន័យប្រតិបត្តិការទំនប់វារីអគ្គិសនីសេសានក្រោម២
- បានពិគ្រោះពិភាក្សាលើការរៀបចំ និងបានលើកកម្ពស់ការយល់ដឹង និងការប្រើប្រាស់ផលិតផល MRC ជូនដល់ក្រសួង-ស្ថាប័ន និងដៃគូពាក់ព័ន្ធនៅថ្នាក់ជាតិ ដែលក្នុងនោះ រួមមាន៖
  - ✓ របាយការណ៍តាមដានសុខភាពអេកូឡូស៊ីរបស់ MRC ឆ្នាំ២០២៣
  - ✓ ការអនុវត្តផែនការសកម្មភាពរួម សម្រាប់គម្រោងទំនប់វារីអគ្គិសនីប៉ាក់ប៉េង ប៉ាក់ឡាយ និងហ្លួងប្រាបាង នៃប្រទេសឡាវ

✓ គម្រោងកិច្ចសហប្រតិបត្តិការឆ្លងដែន សម្រាប់ការគ្រប់គ្រងទឹកជំនន់ និងភាពរាំងស្ងួត នៅតំបន់ព្រំដែនកម្ពុជា-ថៃ ក្នុងអនុអាង 9C-9T

- មន្ត្រីជំនាញអន្តរក្រសួង-ស្ថាប័នកម្ពុជា បានចូលរួមពិភាក្សាជាមួយប្រទេសជាសមាជិកផ្សេងទៀត ស្តីពី(១)ការផ្លាស់ប្តូរនិងចែករំលែកព័ត៌មាន និងការវាយតម្លៃតម្រូវការសមត្ថភាព សម្រាប់ការអនុវត្តជំពូកទី៤ នៃគោលការណ៍ណែនាំបច្ចេកទេសនៃនីតិវិធីសម្រាប់គុណភាពទឹក (២)ការតាមដានភាពសម្បូរត្រី និងភាពចម្រុះប្រភេទត្រីក្នុងអាងទន្លេមេគង្គ ដែលទាំងនេះ ជាសកម្មភាពសំខាន់រួមចំណែកដល់ការយល់ដឹងអំពីស្ថានភាព និងនិន្នាការនៃធនធានបរិស្ថានក្នុងអាងទន្លេមេគង្គ





- រាល់កិច្ចជំនួបពិភាក្សាការងារជាមួយភាគីពាក់ព័ន្ធ អគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក តែងបានផ្តល់ជូន និងចែកផ្សាយនូវឯកសារសំខាន់ រួមមាន ព្រឹត្តប័ត្រព័ត៌មានស្ថាប័ន ផែនការយុទ្ធសាស្ត្រឆ្នាំ២០២៤-២០២៨ ផែនការចង្អុលថ្នាក់ជាតិឆ្នាំ២០២១-២០២៥ របាយការណ៍ សកម្មភាពការងារ និងសមិទ្ធផលប្រចាំឆ្នាំកន្លងមក និងផែនការការងារប្រចាំឆ្នាំ កិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ នីតិវិធីស្តីពីការគ្រប់គ្រងការប្រើប្រាស់ទឹកយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងឆ្នាំ២០២១-២០៣០ និងឯកសារគោលការណ៍ណែនាំពាក់ព័ន្ធនានាផ្សេងទៀត



- ដោយមានការជូនដំណឹងពីលេខាធិការដ្ឋាន MRC អំពីការបំពុលដោយសារជាតុលោហៈធ្ងន់ក្នុងទន្លេកុក និងទន្លេសៃ ក្នុងប្រទេសថៃ និងទន្លេមេគង្គ, គ.ជ.ទ.ម.ក បានជូនដំណឹងបន្តទៅក្រសួងធនធានទឹក និងឧតុនិយម និងបានស្នើឱ្យលេខាធិការដ្ឋាន MRC ត្រូវបន្តតាមដានដោយការយកចិត្តទុកដាក់ខ្ពស់ និងត្រូវជូនដំណឹងមកប្រទេសជាសមាជិក ឱ្យបានទាន់ពេលវេលា ដើម្បីមានវិធានការសមស្របក្នុងករណីមានផលប៉ះពាល់ឆ្លងដែនមកប្រទេសតាមដងទន្លេមេគង្គនៅភាគខាងក្រោម។

ការយកចិត្តទុកដាក់ចំពោះការលើកកម្ពស់ការយល់ដឹង និងការផ្សព្វផ្សាយ គឺជាសកម្មភាពមួយដ៏សំខាន់ និងជាអាទិភាព ដើម្បីបង្កើនការយល់ដឹងឱ្យបានកាន់ទូលំទូលាយ មានការចូលរួមកាន់តែសកម្ម ដែលនេះពិតជាមានសារៈសំខាន់ អាចជួយគាំទ្រ ពង្រឹងនិងលើកកម្ពស់ការចូលរួម និងកិច្ចសហការក្នុងការគ្រប់គ្រងធនធានធម្មជាតិនិងអាងទន្លេ បានកាន់តែប្រសើរ មានប្រសិទ្ធភាព និងប្រកបដោយបរិយាបន្ន។

### ឃ/. ការពង្រឹងសមត្ថភាព និងការបណ្តុះបណ្តាលធនធានមនុស្ស

- មន្ត្រីវ័យក្មេងកម្ពុជាចំនួន ៣រូប ត្រូវបានចាត់បញ្ជូនបំពេញកម្មសិក្សាការងារលើផ្នែកជំនាញរយៈពេល១ឆ្នាំ ក្នុងឆ្នាំ ២០២៥ នៅលេខាធិការដ្ឋាន MRC នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ និងនៅមជ្ឈមណ្ឌលគ្រប់គ្រងទឹកជំនន់ និងភាពរាំងស្ងួតប្រចាំតំបន់ នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា លើផ្នែកប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ម៉ូដែលធនធានទឹក និងការព្យាករទឹកជំនន់ និងភាពរាំងស្ងួត និងបានចាត់បញ្ជូន ៣រូបផ្សេងទៀត ទៅបំពេញកម្មសិក្សារយៈពេល១ឆ្នាំ សម្រាប់ឆ្នាំ២០២៦
- បានពង្រឹង លើកកម្ពស់សមត្ថភាពជំនាញមន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក និងក្រសួង-ស្ថាប័នពាក់ព័ន្ធ តាមរយៈការចាត់ទៅចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលបច្ចេកទេសទាំងថ្នាក់ជាតិ និងថ្នាក់តំបន់ លើផ្នែកការគ្រប់គ្រងទឹកឆ្លងដែន ការព្យាករទឹកជំនន់និងភាពរាំងស្ងួត អេកូឡូស៊ី ផែនការគ្រប់គ្រងបរិស្ថាន ជលផល ការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងការបំពុលទឹក សុវត្ថិភាពទំនប់ ការប្រើប្រាស់ក្របខ័ណ្ឌគាំទ្រការធ្វើសេចក្តីសម្រេចចិត្ត និងឧបករណ៍បច្ចេកទេស ព្រមទាំងលើផ្នែកភាពជាអ្នកដឹកនាំ ការប្រាស្រ័យទាក់ទង គ្រប់គ្រងរដ្ឋបាល និងការិយាល័យ ការធ្វើបទបង្ហាញ ការគ្រប់គ្រងគម្រោង ការគ្រប់គ្រងការផ្លាស់ប្តូរ ការគ្រប់គ្រងទំនាស់ជាដើម
- មន្ត្រីជំនាញអន្តរក្រសួង-ស្ថាប័នកម្ពុជា បានចូលរួមក្នុងក្រុមប្រតិភូនៃប្រទេសជាសមាជិក និងលេខាធិការដ្ឋាន MRC ក្នុងទស្សនកិច្ចសិក្សានៅអាងទន្លេអន្តរជាតិនៅអឺរ៉ុប ក្នុងប្រទេសជាសមាជិក ក្នុងប្រទេសនិងនៅមូលដ្ឋាន ដើម្បីស្វែងយល់អំពីការគ្រប់គ្រងទឹកនិងអាងទន្លេឆ្លងដែន ទឹកជំនន់ ធនធានធម្មជាតិ ជាដើម។ ដែលនេះជាផ្នែកមួយដើម្បីការពង្រឹងកិច្ចសហប្រតិបត្តិការបណ្តាញទំនាក់ទំនងការងារ និងភាពជាដៃគូ និងក៏ជាឱកាសដើម្បីផ្លាស់ប្តូរបទពិសោធន៍ ចំណេះដឹង និងជំនាញផងដែរ លើការគ្រប់គ្រងទឹក អាងទន្លេ នៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងតំបន់ ផងដែរ



ការពង្រឹងសមត្ថភាព ចំណេះដឹង និងបទពិសោធន៍លើផ្នែកការគ្រប់គ្រងធនធានទឹក និងអាងទន្លេ ដល់មន្ត្រីបច្ចេកទេស និងអ្នករៀបចំគោលនយោបាយនៅថ្នាក់ជាតិសម្រាប់កម្ពុជា តាមរយៈកម្មសិក្សាការងារជំនាញ ការបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាជាដើម គឺជាការរួមចំណែកដ៏សំខាន់ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំ និងការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹក និងធនធានពាក់ព័ន្ធក្នុងអាងទន្លេមេគង្គ ឆ្ពោះទៅ

សម្រេចបាននូវគោលបំណងដើម្បីធានាឱ្យបាននូវនិរន្តរភាពនៃធនធានទឹក និងអាងទន្លេសម្រាប់ជាផលប្រយោជន៍ នៃសហគមន៍ ប្រជាជន និងបណ្តាប្រទេសតាមដងទន្លេ និងអាងទាំងមូល ទាំងពេលបច្ចុប្បន្ន និងនាពេលអនាគត។

ខាងក្រោមនេះ គឺជាតារាងអំពីព្រឹត្តការណ៍ប្រចាំឆ្នាំ២០២៥ ដែល គ.ជ.ទ.ម.ក បានរៀបចំ និងចាត់មន្ត្រីចូលរួម។ តួលេខក្នុងតារាងនេះ ឆ្លុះបញ្ចាំងនូវសារៈសំខាន់នៃការពិគ្រោះយោបល់កាន់តែទូលាយ បង្កើននូវការចូលរួម និងកិច្ចសហការណ៍ ព្រមទាំងការយកចិត្តទុកដាក់លើការលើកកម្ពស់ការយល់ដឹង និងការពង្រឹងសមត្ថភាពជំនាញ ដែលជាការរួមចំណែកក្នុងបេសកកម្ម ដើម្បីចីរភាពនៃអាងទន្លេមេគង្គ និងធនធានក្នុងអាង ទ្រទ្រង់ដល់ការអភិវឌ្ឍ និងវិបុលភាពរួមគ្នា ក្នុងតំបន់មេគង្គ។

| ២០២៥ | កិច្ចប្រជុំ និងសិក្ខាសាលា | | | | ទស្សនកិច្ច | | វគ្គបណ្តុះបណ្តាល | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ថ្នាក់ជាតិ | | ថ្នាក់តំបន់ | | ថ្នាក់ជាតិ | ថ្នាក់តំបន់ | ថ្នាក់ជាតិ | | ថ្នាក់តំបន់ | |
| | CNMC | Other | MRC | Other | | | CNMC | Other | MRC | Other |
| | 43 | 117 | 61 | 7 | 8 | 9 | 8 | 11 | 6 | 2 |
| សរុប | 160 | | 68 | | 17 | | 19 | | 8 | |
| ចំនួនអ្នកចូលរួម | 645 | 175 | 366 | 10 | 120 | 26 | 156 | 55 | 30 | 4 |

*កំណត់សម្គាល់៖ CNMC-គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា, MRC-គណៈកម្មការទន្លេមេគង្គ, Other-ក្រសួង ស្ថាប័ន និងដៃគូផ្សេងៗ*

### ៤.២ បញ្ហាប្រឈម

ទន្ទឹមនឹងវឌ្ឍនភាពការងារ និងសមិទ្ធផលសំខាន់ៗដែលសម្រេចដូចបានរៀបរាប់ខាងលើ ក៏មាននូវបញ្ហាប្រឈមមួយចំនួនបានជួបប្រទះដូចខាងក្រោម ដែលចាំបាច់ត្រូវបន្តយកចិត្តទុកដាក់ខ្ពស់ ដើម្បីធានានូវប្រសិទ្ធភាពក្នុងកិច្ចដំណើរការការងារស្ថាប័ន និងកិច្ចសហប្រតិបត្តិការ ឆ្ពោះទៅសម្រេចឱ្យបានការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គប្រកបដោយចីរភាព និងភាពធន់ទៅនឹងអាកាសធាតុ សម្រាប់ពេលបច្ចុប្បន្ន និងទាំងក្នុងពេលអនាគត៖

- សន្ទុះនៃការអភិវឌ្ឍក្នុងអាងទន្លេមេគង្គ និងក្នុងប្រទេសតាមដងទន្លេ មានការកើនឡើងជាបន្តបន្ទាប់គួរឱ្យកត់សម្គាល់ ដែលកត្តាទាំងនេះគួបផ្សំនឹងការប្រែប្រួលអាកាសធាតុ អាចដាក់សម្ពាធមកលើនិរន្តរភាពនៃធនធានធម្មជាតិ និងអាងទន្លេ ដែលចាំបាច់ត្រូវបង្កើនការយកចិត្តទុកដាក់ និងរួមគ្នាគិតគូរដោះស្រាយក្នុងស្មារតីនៃកិច្ចសហប្រតិបត្តិការកាន់តែរឹងមាំថែមទៀត
- ដំណើរការគ្រប់គ្រងការអភិវឌ្ឍ និងការកសាងផែនការអាងទន្លេផ្អែកតាមគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ ចាំបាច់ត្រូវមានការចូលរួម និងកិច្ចសហការពីគ្រប់ភាគីពាក់ព័ន្ធក្នុងប្រទេស និងក្នុងតំបន់អាងទន្លេទាំងមូល ដែលដំណើរការនេះចាំបាច់ត្រូវពង្រឹង និងធ្វើឱ្យប្រសើរបន្ថែមទៀត
- តំបន់អាងទន្លេមេគង្គទាំងមូល ចាំបាច់ត្រូវមានការចែករំលែកទិន្នន័យ និងព័ត៌មាន ជាពិសេស ផ្នែកជលសាស្ត្រ-ឧតុនិយម ប្រតិបត្តិការទំនប់ និងហេដ្ឋារចនាសម្ព័ន្ធទឹកពាក់ព័ន្ធផ្សេងទៀត ដែលនេះពិតជាមានសារៈសំខាន់ ជួយគាំទ្រដល់ការរៀបចំផែនការគ្រប់គ្រងអាងទន្លេរួម ការពិនិត្យតាមដាននិងការធ្វើសេចក្តីសម្រេច និងការពង្រឹងនិង

ធ្វើឱ្យប្រសើរលើការព្យាករ ការជូនដំណឹងជាមុន និងការត្រៀមបង្ការនូវហានិភ័យ និងគ្រោះធម្មជាតិ ដូចជាទឹកជំនន់ ភាពរាំងស្ងួតជាដើម ទាំងក្នុងកម្រិតអាង និងសម្រាប់ប្រទេសតាមដងទន្លេ ផងដែរ

- ការងារវិមជ្ឈការមុខងារស្នូលគ្រប់គ្រងអាងទន្លេសម្រាប់ថ្នាក់ជាតិ បាននិងកំពុងអនុវត្ត ដែលការណ៍នេះនឹងបង្កើនការទទួលខុសត្រូវផ្នែកថវិកានិងបច្ចេកទេសដោយប្រទេសជាសមាជិក MRC រៀងៗខ្លួន ស្របពេលដែលការគាំទ្រផ្នែកហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍កាន់តែថយចុះ និងស្របតាមការប្ដេជ្ញាចិត្តរបស់ប្រមុខរដ្ឋាភិបាល នៃប្រទេសជាសមាជិក MRC លើស្វ័យភាពផ្នែកហិរញ្ញវត្ថុទាំងស្រុងដោយប្រទេសជាសមាជិក នៅឆ្នាំ២០៣០
- កិច្ចសម្របសម្រួលរវាងថ្នាក់ជាតិ និងថ្នាក់តំបន់ សម្រាប់ការអនុវត្តផែនការការងារតំបន់ ពេលខ្លះត្រូវការពេលវេលាច្រើនក្នុងការពិគ្រោះយោបល់ក្នុងចំណោមប្រទេសជាសមាជិក និងដៃគូសហការផ្សេងទៀត ដែលការណ៍នេះទាមទារឱ្យប្រទេសជាសមាជិកត្រូវពិភាក្សាគ្នាក្នុងពេលវេលាដ៏សមគួរជាមុន
- យន្តការតំបន់ពាក់ព័ន្ធនឹងមេគង្គមានច្រើន ដែលបាននិងកំពុងដំណើរការក្នុងតំបន់មេគង្គ ដែលការណ៍នេះ ទាមទារឱ្យមានការយកចិត្តទុកដាក់ និងបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងស្មារតីទទួលខុសត្រូវខ្ពស់បន្ថែមទៀត
- ទំហំការងារមានការកើនឡើង និងមន្ត្រីមួយចំនួនត្រូវចូលនិវត្តន៍ ដែលការណ៍នេះ ចាំបាច់ត្រូវជ្រើសរើសបំពេញបន្ថែម និងបន្តពង្រឹងសមត្ថភាពជាប្រចាំ លើផ្នែកជំនាញ បច្ចេកទេស ដើម្បីទ្រទ្រង់ដល់កិច្ចដំណើរការការងាររបស់ស្ថាប័ន បានកាន់តែប្រសើរ និងដើម្បីចូលរួមសហការក្នុងកម្រិតតំបន់ និងអន្តរជាតិ កាន់តែមានប្រសិទ្ធភាព។

## ៥. ការបូកសរុប និងសេចក្ដីសន្និដ្ឋាន

ក្នុងឆ្នាំ២០២៥ គ.ជ.ទ.ម.ក បានអនុវត្តការងាររបស់ខ្លួនប្រកបដោយការទទួលខុសត្រូវ ដោយនៅថ្នាក់ជាតិបានសហការយ៉ាងជិតស្និត និងមានការចូលរួមយ៉ាងសកម្មពីក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធនានា និងនៅថ្នាក់តំបន់ក្រោមយន្តការ MRC បានសហការជាមួយលេខាធិការដ្ឋាន MRC បណ្ដាប្រទេសជាសមាជិកផ្សេងទៀត (ឡាវ ថៃ និងវៀតណាម) ប្រទេសដៃគូសន្ទនា (ចិន និងមីយ៉ាន់ម៉ា) ដៃគូអភិវឌ្ឍន៍ យន្តការតំបន់និងអន្តរជាតិ ព្រមទាំងដៃគូសហការពាក់ព័ន្ធនានា ដោយទទួលបាននូវវឌ្ឍនភាពការងារគួរឱ្យកត់សម្គាល់ និងសមិទ្ធផលសំខាន់ថ្មីៗជាច្រើនបន្ថែមទៀត ក្នុងការជំរុញលើកកម្ពស់កិច្ចសហប្រតិបត្តិការ កិច្ចខិតខំប្រឹងប្រែងរួម និងភាពជាដៃគូទាំងនៅថ្នាក់ជាតិ និងក្របខ័ណ្ឌតំបន់ ក្នុងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ និងនីតិវិធីគ្រប់គ្រងការប្រើប្រាស់ទឹក ផែនការ និងសកម្មភាពជាអាទិភាពរបស់ MRC ដើម្បីការគ្រប់គ្រង និងការអភិវឌ្ឍប្រកបដោយចីរភាពក្នុងអាងទន្លេមេគង្គ។

សមិទ្ធផលក្នុងក្របខ័ណ្ឌតំបន់ និងដោយឡែកសម្រាប់កម្ពុជា ដែលសម្រេចបានក្នុងឆ្នាំ២០២៥ គឺបានមកពីកិច្ចសហការ ការគាំទ្រ និងការចូលរួមយ៉ាងសកម្ម និងប្រកបដោយប្រសិទ្ធភាព ពីបណ្ដាក្រសួង-ស្ថាប័នជាសមាជិក គ.ជ.ទ.ម.ក អាជ្ញាធរដែនដី និងដៃគូពាក់ព័ន្ធផ្សេងទៀត ព្រមទាំងការយកចិត្តទុកដាក់ និងកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ មន្ត្រីបុគ្គលិក គ.ជ.ទ.ម.ក នៅគ្រប់កម្រិត ក្នុងការបំពេញតួនាទីភារកិច្ច ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ និងមានប្រសិទ្ធភាព។

ក្នុងឆ្នាំ២០២៦ ខាងមុខ គ.ជ.ទ.ម.ក នឹងត្រូវបន្តអនុវត្តផែនការការងាររបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត ដើម្បីរួមចំណែកគាំទ្រក្នុងបេសកកម្មរួម ឆ្ពោះទៅសម្រេចឱ្យបាននូវការអភិវឌ្ឍដោយចីរភាព និងការធ្វើឱ្យប្រសើរ

នូវស្ថានភាពបរិស្ថាន សង្គម និងសេដ្ឋកិច្ច ប្រកបដោយភាពធន់ នឹងការប្រែប្រួលអាកាសធាតុ ក្នុងអាងទន្លេមេគង្គទាំងមូល និងក្នុងប្រទេសកម្ពុជា សម្រាប់ពេលបច្ចុប្បន្ន និងនាពេលអនាគត។

## ៦. ទិសដៅការងារអនុវត្តបន្តឆ្នាំ២០២៦

ដើម្បីរួមចំណែកគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ឆ្នាំ២០២៤-២០២៨ របស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា និងដើម្បីបន្តចូលរួមអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេថ្នាក់តំបន់ ឆ្នាំ២០២១-២០៣០ និងយុទ្ធសាស្ត្រ និងផែនការមេតាមវិស័យ (ជលផលបរិស្ថាន នាវាចរណ៍ វារីអគ្គិសនី ការប្រែប្រួលអាកាសធាតុ ទឹកជំនន់ រាំងស្ងួត) របស់ MRC, គ.ជ.ទ.ម.ក នឹងបន្តខិតខំប្រឹងប្រែងអនុវត្តនូវទិសដៅ និងការងារជាអាទិភាពដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្ររបស់ខ្លួនឆ្នាំ២០២៤-២០២៨ ដោយក្នុងនោះ សម្រាប់ឆ្នាំ២០២៦, គ.ជ.ទ.ម.ក បានកំណត់ទិសដៅអនុវត្តបន្ត ដោយផ្តោតលើការងារជាអាទិភាព ដូចខាងក្រោម៖

- បន្តពង្រឹង លើកកម្ពស់សមត្ថភាពធនធានមនុស្ស និងប្រសិទ្ធភាពនៃកិច្ចដំណើរការស្ថាប័ន
- បន្តពង្រឹង លើកកម្ពស់កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ ឱ្យបានកាន់តែរឹងមាំនិងប្រសើរថែមទៀតក្នុងកិច្ចខិតខំប្រឹងប្រែងរួមដើម្បីការគ្រប់គ្រង និងអភិវឌ្ឍន៍ដោយចីរភាព ក្នុងអាងទន្លេមេគង្គ
- បន្តលើកកម្ពស់ការចូលរួម និងកិច្ចពិគ្រោះយោបល់ក្នុងដំណើរការអនុវត្ត រៀបចំធ្វើបច្ចុប្បន្នភាព ផែនការយុទ្ធសាស្ត្រ គោលការណ៍ណែនាំ និងឧបករណ៍បច្ចេកទេស ក្នុងការគ្រប់គ្រងធនធានទឹកចម្រុះ និងអាងទន្លេ
- បន្តពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានប្រតិបត្តិសម្រាប់ការគ្រប់គ្រងការប្រើប្រាស់ទឹក និងអាងទន្លេឱ្យបានកាន់តែប្រសើរថែមទៀត
- បន្តសហការក្នុងកិច្ចដំណើរការ និងការធ្វើឱ្យប្រសើរលើការពិនិត្យតាមដានទន្លេ និងស្ថានភាពធនធានធម្មជាតិក្នុងអាង
- បន្តលើកកម្ពស់ការយល់ដឹង ការផ្សព្វផ្សាយ និងការប្រើប្រាស់ផលិតផលសម្រេចបានតាមវិស័យ និងផ្នែករបស់ MRC ដើម្បីគាំទ្រ និងពង្រឹងការគ្រប់គ្រង ការប្រើប្រាស់ ការអភិវឌ្ឍ និងការអភិរក្សធនធានទឹក ធនធានពាក់ព័ន្ធ និងអាងទន្លេ
- សហការពិនិត្យតាមដានវឌ្ឍនភាព និងប្រសិទ្ធភាពការងារនៅថ្នាក់ជាតិ និងតំបន់ និងការរៀបចំផែនការការងារបន្ត។

ដើម្បីអនុវត្តការងារជាអាទិភាពរបស់ខ្លួនក្នុងឆ្នាំ២០២៦ ប្រកបដោយប្រសិទ្ធភាព និងទទួលបានជោគជ័យបន្ថែមទៀត, គ.ជ.ទ.ម.ក បន្តខិតខំប្រឹងប្រែងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ដោយនឹង៖

- បន្តយកចិត្តទុកដាក់លើការបន្តកសាង អភិវឌ្ឍន៍ និងពង្រឹងសមត្ថភាពធនធានមនុស្ស និងស្ថាប័ន,
- បន្តកសាង និងពង្រឹងទំនាក់ទំនង កិច្ចសហការ និងភាពជាដៃគូ ឱ្យបានកាន់តែរឹងមាំនិងប្រសើរថែមទៀតជាមួយគ្រប់ភាគី និងដៃគូពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិ និងថ្នាក់តំបន់ និង
- ពិនិត្យតាមដាន និងបន្តពង្រឹងប្រសិទ្ធភាពការងារជាប្រចាំ និងឱ្យបានកាន់តែប្រសើរឡើងថែមទៀត៕

#576, National Road No 2, Sangkat Chak Angre Krom, Khan Meanchey,

Phnom Penh, Cambodia

Website: http://www.cnmc.gov.kh